ជំពូកទី ១៦

# ភ្នែក




## សញ្ញាគ្រោះថ្នាក់

ភ្នែកជាសរីរាង្គមួយដែលងាយនឹងខូចណាស់ ហើយត្រូវការការថែរក្សាយ៉ាងត្រឹមត្រូវ។ ត្រូវរកជំនួយពីគ្រូពេទ្យឲ្យបានលឿន នៅពេលមានសញ្ញាគ្រោះថ្នាក់ណាមួយដូចខាងក្រោមនេះ កើតឡើង ៖

១. របួសដែលដាច់រហែក ឬធ្លាយទៅដល់គ្រាប់ភ្នែក។

២. មានចំណុចពណ៌ប្រផេះ និងមានការឈឺចាប់នៅលើគ័រនេ ព្រមទាំងមានពណ៌ក្រហមនៅជុំវិញគ័រនេ (ដំបៅគ័រនេ)។

៣. មានការឈឺចាប់យ៉ាងខ្លាំងនៅក្នុងភ្នែក (អាចជាជំងឺរលាកប្រស្រីភ្នែក ឬគ្លូកូម)។

៤. មានទំហំខុសគ្នាយ៉ាងខ្លាំងនៃកូនក្រមុំទាំងពីរ ពេលមានអាការឈឺក្បាល ឬឈឺក្នុងភ្នែក។



*ការមានទំហំខុសគ្នាយ៉ាងខ្លាំងនៃកូនក្រមុំទាំងពីរ អាចបណ្តាលមកពីមានការខូចខួរក្បាល ជំងឺដាច់សរសៃឈាមខួរក្បាល របួសភ្នែក ជំងឺគ្លូកូម ឬរលាកប្រស្រីភ្នែក។ (ការមានទំហំកូនក្រមុំភ្នែកខុសគ្នា បន្តិចបន្តួច អាចជាការធម្មតា ចំពោះមនុស្សខ្លះ)។*

៥. មានឈាមនៅពីក្រោយគ័រនេ ខាងក្នុងគ្រាប់ភ្នែក(មើលទំ.២២៥)។

៦. បើភ្នែកម្ខាង ឬទាំងសងខាងចាប់ផ្តើមមើលមិនច្បាស់។

៧. មានផ្សែងសៗ ឬមានចំណាំងនៅក្នុងប្រស្រីភ្នែក។ នេះអាចជារោគសញ្ញានៃជំងឺមហារីក(retinoblastoma) ឬជំងឺភ្នែកឡើងបាយ(មើលទំ.២២៥)។



៨. ការបង្ករោគក្នុងភ្នែកឬការរលាកដែលគ្មានការធូរស្រាលដោយការព្យាបាលដោយថ្នាំក្រមួនអង់ទីប៊ីយ៉ូទិក ៥ឬ៦ថ្ងៃ។

# ការមានរបួសភ្នែក

រាល់ការមានរបួសដល់គ្រាប់ភ្នែក ត្រូវចាត់ទុកថាមានគ្រោះថ្នាក់ ព្រោះវាអាចបណ្តាលឲ្យខ្វាក់ភ្នែក។

ទោះបីជាការមានរបួសបន្តិចបន្តួចលើ**គ័រនេ**ក៏ដោយ(ស្រទាប់ថ្លាគ្របពីលើកូនក្រមុំនិងប្រស្រីភ្នែក) ក៏អាចធ្វើឲ្យមានការបង្ករោគ និងប៉ះពាល់ដល់គំហើញដែរ ប្រសិនបើគ្មានការព្យាបាលត្រឹមត្រូវទេ។

បើការមានរបួសដល់គ្រាប់ភ្នែកនោះ មានជម្រៅជ្រៅ ដែលចូលទៅដល់ស្រទាប់ខ្មៅ ខាងក្រោមស្រទាប់ខាងក្រៅពណ៌ស នោះវាជាគ្រោះថ្នាក់ពិសេសមួយ។

បើវាជាការខ្ទាំ (ដូចការដាល់នឹងកណ្តាប់ដៃ) ដែលបណ្តាលឲ្យមានការខ្ទាំឈាមនៅគ្រាប់ភ្នែកនោះ ភ្នែកនោះនឹងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់(ទំ.២២៥)។ គ្រោះថ្នាក់នេះមានសភាពកាន់តែធ្ងន់ធ្ងរ ប្រសិនបើការឈឺចាប់កាន់តែខ្លាំងឡើងៗ បន្ទាប់ពី២ទៅ៣ថ្ងៃ ព្រោះនេះអាចជាជំងឺគ្លូកូម(ទំ.២២២)។

*ការព្យាបាល ៖*



- បើភ្នែកដែលត្រូវរបួសនៅតែមើលឃើញច្បាស់ ដាក់ក្រមួនភ្នែកអង់ទីប៊ីយ៉ូទិក(ទំ.៣៧៨) ទៅក្នុងភ្នែក ហើយគ្របវាដោយកំប្រេសទន់ក្រាស់ៗ។ បើភ្នែកនោះគ្មានការធូរស្រាលក្នុងរយៈពេល១ឬ២ថ្ងៃទេ ត្រូវរកជំនួយពីគ្រូពេទ្យជាបន្ទាន់។
- បើភ្នែកដែលរបួសនោះមិនអាចមើលឃើញច្បាស់ បើរបួសមានជម្រៅជ្រៅ ឬបើមានឈាមនៅខាងក្នុងភ្នែក ខាងក្រោយគ័រនេ (ទំ.២២៥) គ្របភ្នែកនោះដោយកំប្រេសស្អាត ហើយទៅរកជំនួយពីគ្រូពេទ្យជាបន្ទាន់។ **កុំសង្កត់លើភ្នែកឲ្យសោះ។**
- **កុំ**ព្យាយាមយកបន្លា ឬអំបែងផ្សេងៗ ដែលជាប់នៅគ្រាប់ភ្នែកនោះចេញ។ ត្រូវរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

# របៀបយកកំទេចធូលីចេញពីភ្នែក

ឲ្យអ្នកនោះបិទភ្នែក ហើយមើលទៅខាងឆ្វេង ខាងស្តាំ ទៅលើ និងទៅក្រោម។ បន្ទាប់មកនៅពេលអ្នកបើកភ្នែករបស់គាត់ ឲ្យគាត់មើលទៅលើ ហើយបន្ទាប់មក ទៅក្រោមវិញ។ ការធ្វើរបៀបនេះនឹងធ្វើឲ្យភ្នែកបញ្ចេញទឹកភ្នែកជាច្រើន ហើយភាគច្រើនកំទេចធូលីនឹងចេញមកដោយឯកឯង។

ឬអ្នកអាចសាកល្បងយកកំទេចធូលីឬគ្រាប់ខ្សាច់នោះចេញ ដោយបើកភ្នែកក្នុងទឹកស្អាត(ទំ.២១៩) ឬដោយប្រើជាយក្រណាត់ស្អាត ឬសំឡីសើម។ ប្រសិនបើកំទេចធូលីស្ថិតនៅខាងក្រោមគ្របកភ្នែកខាងលើ រកមើលវាដោយពន្លាត់គ្របកភ្នែកឡើងលើ ដោយទ្រាប់ឈើតូចមួយពីក្រោម។ អ្នកនោះគួរក្រឡេកមើលទៅក្រោម នៅពេលដែលអ្នកកំពុងធ្វើរបៀបនេះ ៖



*គេច្រើនរកឃើញកំទេចធូលីនៅផ្ទៃត្របកភ្នែក។ យកវាចេញដោយជាយក្រណាត់ស្អាត។*

ប្រសិនបើអ្នកមិនអាចយកកំទេចធូលីចេញដោយងាយទេ ប្រើក្រមួនអង់ទីប៊ីយ៉ូទិកដាក់ភ្នែក គ្របភ្នែកដោយកំប្រេសស្អាត រួចរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

## ការរលាកភ្នែកដោយសារធាតុគីមី



ទឹកអាស៊ីតអាគុយ ទឹកក្បុង ប្រេងសាំង ឬថ្នាំសម្លាប់សត្វល្អិត ដែលចូលទៅក្នុងភ្នែកអាចធ្វើឲ្យមានគ្រោះថ្នាក់។ ត្រូវបើកចំហរភ្នែកឲ្យជាប់។ **ហើយចាក់ទឹកស្អាតត្រជាក់ ចូលទៅក្នុងភ្នែកភ្លាមៗ។ ត្រូវចាក់ទឹករយៈពេល៣០នាទី** ឬចាក់រហូតដល់លែងមានការឈឺចាប់។ មិនត្រូវឲ្យទឹកដែលចាក់នោះហូរចូលទៅក្នុងភ្នែកម្ខាងទៀតទេ។

## ភ្នែកក្រហម និងមានការឈឺចាប់ - មូលហេតុផ្សេងៗ

មានបញ្ហាជាច្រើនដែលបណ្តាលឲ្យមានភ្នែកក្រហមនិងឈឺចាប់។ ការព្យាបាលដ៏ត្រឹមត្រូវ គឺផ្អែកលើការរកឃើញមូលហេតុរបស់វា។ ដូច្នេះត្រូវប្រាកដថាបានពិនិត្យមើលយ៉ាងយកចិត្តទុកដាក់នូវរោគសញ្ញានីមួយៗ។ តារាងនេះអាចជួយអ្នកឲ្យរកឃើញមូលហេតុនៃជំងឺភ្នែក ៖

| | |
|---|---|
| វត្ថុផ្សេងៗ(កំទេចធូលីជាដើម)<br>ដែលចូលទៅក្នុងភ្នែក(ទំ.២១៨) | តាមទូទៅ ប៉ះពាល់តែ**ភ្នែកម្ខាងប៉ុណ្ណោះ**។<br>ការឡើងក្រហម និងការឈឺចាប់ មិនទៀងទាត់ |
| ការរលាក ឬវត្ថុរាវដែលមាន<br>គ្រោះថ្នាក់ (ទំ.២១៩) | ភ្នែកតែម្ខាង ឬទាំងសងខាង។<br>ការឡើងក្រហម និងការឈឺចាប់ មិនទៀងទាត់ |
| ភ្នែកក្រហមព្រឿងៗ (ជំងឺរលាកផ្ទៃកសនៃភ្នែក ទំ.២១៩)<br>ក្រហមភ្នែក (រលាកផ្ទៃកសនៃភ្នែកដោយអាល់ឡែស៊ី ទំ.១៦៥)<br>ត្រាកូម (ទំ.២២០)<br>កញ្ជ្រឹល (ទំ.៣១១) | ជាទូទៅ **ភ្នែកទាំងពីរ** (អាចចាប់ផ្តើម ឬមានសភាពធ្ងន់ធ្ងរលើភ្នែកម្ខាង)។ ក្រហមខ្លាំងបំផុតនៅគែមខាងក្រៅភ្នែក។ ឈឺក្រហាយ មិនសូវខ្លាំង  |
| ក្លកូមស្រួចស្រាល់ (ទំព័រ២២២)<br>រលាកប្រស្រីភ្នែក(ទំ.២២១ )<br>រលាត់ ឬដំបៅគ័រនេ(ទំ.២២៤) | ជាទូទៅ ប៉ះពាល់តែ**ភ្នែកម្ខាង**។<br>ក្រហមខ្លាំងនៅក្បែរគ័រនេ។<br>ភាគច្រើន មានការឈឺចាប់ខ្លាំង  |

## ភ្នែកក្រហមព្រឿងៗ (ជំងឺរលាកផ្ទៃកសនៃភ្នែក)

ការបង្ករោគនេះបណ្តាលឲ្យភ្នែកក្រហម មានខ្ទុះ និងឈឺក្រហាយបន្តិចបន្តួចនៅភ្នែកម្ខាង ឬទាំងសងខាង។ ត្របកភ្នែកច្រើន តែស្អិតជាប់គ្នាពេលក្រោកពីដេក។ ជំងឺនេះកើតជាញឹកញាប់ចំពោះកុមារ។

*ការព្យាបាល*

ដំបូងត្រូវលាងខ្ទុះចេញពីភ្នែកដោយប្រើក្រណាត់ជ្រើមដោយទឹកឆ្អិន។ បន្ទាប់មកដាក់ក្រមួនអង់ទីប៊ីយ៉ូទិកភ្នែក (ទំ.៣៧៨)។ ទាញត្របកភ្នែកក្រោមចុះក្រោម ហើយដាក់ថ្នាំក្រមួនបន្តិចចូលទៅក្នុងនោះ ដូចរូបនេះ។ ការដាក់ថ្នាំក្រមួនភ្នែកនៅខាងក្រៅភ្នែក មិនមានប្រសិទ្ធភាពអ្វីឡើយ។




*ប្រយត្ន័: កុំឲ្យបំពង់ក្រមួន ប៉ះជាមួយភ្នែក*

*ការការពារ*

ជំងឺភ្នែកក្រហមនេះគឺជាជំងឺឆ្លង។ ការបង្ករោគរបស់វាឆ្លងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតយ៉ាងងាយ។ កុំឲ្យកុមារដែលមានជំងឺភ្នែកក្រហម លេងឬដេកជាមួយកុមារដទៃទៀត ឬប្រើកន្សែងជាមួយគ្នាទេ។ ត្រូវលាងដៃបន្ទាប់ពីមានការប៉ះពាល់ភ្នែក។

# ត្រាកូម

ត្រាកូមគឺជាការបង្ករោគរ៉ាំរ៉ៃមួយ ដែលមានការវិវឌ្ឍន៍យឺតៗ។ វាអាចមានរយៈពេលជាច្រើនខែឬច្រើនឆ្នាំ។ បើគ្មានការព្យាបាលទាន់ពេលទេ វាអាចបណ្តាលឲ្យខ្វាក់ភ្នែក។ ជំងឺនេះឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់ ឬតាមរយៈសត្វរុយ ហើយវាច្រើនកើតនៅកន្លែងដែលមានមនុស្សរស់នៅក្នុងស្ថានភាពមិនល្អនិងផ្តុំគ្នាច្រើន។

*រោគសញ្ញា*

- ត្រាកូមចាប់ផ្តើមឡើងដោយមានភ្នែកក្រហម ហៀរទឹកភ្នែក ដូចជំងឺភ្នែកក្រហមទូទៅដែរ។
- បន្ទាប់ពីមួយខែឬច្រើនជាងនេះមក មានដុំពកតូចៗពណ៌ផ្កាឈូកប្រផេះនៅខាងក្នុងត្របកភ្នែកខាងលើ។ ដើម្បីមើលឃើញដុំទាំងនេះ ត្រូវពន្លាត់ត្របកភ្នែក ដូចបានបង្ហាញនៅទំ.២១៨។
- ផ្នែកសនៃភ្នែក មានពណ៌ក្រហមបន្តិចបន្តួច។
- ពីរបីខែក្រោយមក បើអ្នកពិនិត្យឲ្យបានជិតដល់ ឬដោយកែវពង្រីកអ្នកអាចឃើញថាផ្នែកខាងលើនៃគ័រនេ មានពណ៌ប្រផេះ ពីព្រោះវាមានសរសៃឈាមតូចៗជាច្រើនដែលទើបកើតថ្មីៗនៅកន្លែងនោះ។
- ការរួមបញ្ចូលគ្នានៃសរសៃឈាមថ្មីៗ និងដុំពកតូចៗទាំងនោះ គឺជាត្រាកូមហើយ។
- បន្ទាប់ពីរយៈពេលជាច្រើនឆ្នាំក្រោយមក ដុំពកទាំងនោះចាប់ផ្តើមរលុបបាត់ទៅវិញ ហើយបន្សល់នូវស្នាមពណ៌សៗ។





*ស្នាមទាំងនេះធ្វើឲ្យត្របកភ្នែកទៅជាក្រាស់ ហើយអាចធ្វើឲ្យបើកភ្នែកឬបិទភ្នែករហូត។*



*ឬស្នាមទាំងនេះអាចទាញរោមភ្នែកចូលទៅក្នុងភ្នែក ហើយកោសគ័រនៃ រួចបណ្តាលឲ្យខ្វាក់។*



*វិធីព្យាបាលជំងឺត្រាកូម*

ដាក់ថ្នាំក្រមួនភ្នែកតេត្រាស៊ីគ្លីន( Tetracycline ) ឬក្រមួនភ្នែកអេរីត្រូមីស៊ីន( Erythromycin ) ១% ( ទំ.៣៧៨ ) ទៅក្នុងភ្នែក ៣ដងក្នុងមួយថ្ងៃ ឬដាក់ថ្នាំក្រមួនភ្នែកតេត្រាស៊ីគ្លីន អេរីត្រូមីស៊ីន ៣% ចំនួន១ដងក្នុងមួយថ្ងៃ។ ធ្វើរបៀបនេះរយៈពេល៣០ថ្ងៃ។ សម្រាប់ការព្យាបាលឲ្យជាជាស្ថាពរ ត្រូវលេបថ្នាំតេត្រាស៊ីគ្លីន( Tetracycline ទំ.៣៥៦ ) ឬអេរីត្រូមីស៊ីន ( Erythromycin ទំ.៣៥៥ ) ឬស៊ុលហ្វាណាមីដ( Sulfonamide ទំ.៣៥៨ ) រយៈពេល២ទៅ៣អាទិត្យផងដែរ។

*វិធីការពារ*

ការព្យាបាលជំងឺត្រាកូមឲ្យបានពេញលេញនិងឲ្យទាន់ពេល គឺជួយបង្ការការឆ្លងរាលដាលទៅអ្នកដទៃ។ មនុស្សទាំងអស់ដែលរស់នៅជាមួយអ្នកមានជំងឺត្រាកូម ជាពិសេសកុមារ គួរពិនិត្យភ្នែកឲ្យបានញឹកញាប់ ហើយប្រសិនបើមានរោគសញ្ញាលេចឡើង ពួកគេគួរព្យាបាលឲ្យបានទាន់ពេល។ ការលាងសម្អាតមុខជារៀងរាល់ថ្ងៃ អាចជួយបង្ការជំងឺត្រាកូមបាន។ ជាមួយគ្នានេះដែរ ការធ្វើតាមការណែនាំអំពីក្បួនអនាម័យ ដែលមានពន្យល់នៅជំពូក១២នោះ គឺជាការសំខាន់ណាស់។

**អនាម័យអាចជួយបង្ការជំងឺត្រាកូម។**

# ការបង្ករោគលើភ្នែកទារក (ជំងឺភ្នែកក្រហមលើទារក)



ប្រសិនបើម្ដាយម្នាក់មាន**ជំងឺប្រមេះទឹកបាយ** ឬ**ក្លាមីដ្យា**(Chlamydia) (មើលទំ. ២៣៦) គាត់អាចចម្លងជំងឺទាំងនេះទៅកូនគាត់បាននៅពេលសម្រាល។ ជំងឺនេះឆ្លងចូលទៅក្នុងភ្នែករបស់ទារក ហើយអាចបណ្ដាលឲ្យខ្វាក់ភ្នែក និងមានបញ្ហាសុខភាពផ្សេងៗទៀត។ បើភ្នែករបស់ទារក ឡើងក្រហម ហើម និងមានខ្ទុះជាច្រើន នៅក្នុងភ្នែក ក្នុងអំឡុងពេលមួយខែដំបូង ទារកនោះអាចមានការបង្ករោគណាមួយឬមានការបង្ករោគទាំងពីរខាងលើនេះ។ ការសំខាន់បំផុតគឺត្រូវផ្ដល់ការព្យាបាលភ្លាមៗ។

*ការព្យាបាលជំងឺប្រមេះទឹកបាយ*

- ចាក់ថ្នាំសេហ្វទ្រីយ៉ាហ្សូន១២៥មីលីក្រាម (Ceftriaxone 125mg) នៅសាច់ដុំភ្លៅ តែម្ដងគត់(មើលទំ.៣៦០)។

*ការព្យាបាលជំងឺក្លាមីដ្យា*

- ឲ្យថ្នាំស៊ីរ៉ូអេរីត្រូមីស៊ីន ៣០មីលីក្រាម(Erythromycin 30mg.) ៤ដងក្នុង១ថ្ងៃ រយៈពេល១៤ថ្ងៃ(ទំ.៣៦០)។

ប្រសិនបើអ្នកមិនអាចពិនិត្យឲ្យដឹងថាជំងឺណាមួយបណ្ដាលឲ្យមានការបង្ករោគនេះ ឲ្យថ្នាំសម្រាប់ជំងឺទាំងពីរ។ ភ្នែករបស់ទារកក៏ត្រូវតែសម្អាត និងព្យាបាលដោយថ្នាំដែលបានរៀបរាប់ខាងក្រោមនេះ។

*វិធីការពារ*

មានស្ត្រីជាច្រើនកើតជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យា ហើយគាត់មិនដឹងខ្លួនថាបានឆ្លងជំងឺនេះឡើយ។ ឲ្យថ្នាំភ្នែកដល់ទារកទាំងអស់ ដើម្បីបង្ការការខ្វាក់ភ្នែក(ទំ.៣៧៩) លើកលែងតែក្នុងករណីដែលម្ដាយបានពិនិត្យមើលដឹងថាគ្មានជំងឺទាំងនេះ។ **ដើម្បីបង្ការការខ្វាក់ភ្នែក** ត្រូវ ៖

- ដាក់ថ្នាំក្រមួនអេរីត្រូមីស៊ីន ០,៥% ទៅ១% ទៅក្នុងភ្នែកទាំងសងខាងរបស់ទារក ក្នុងអំឡុង២ម៉ោងដំបូងបន្ទាប់ពីសម្រាល។ ***ឬ***
- ដាក់ថ្នាំក្រមួនភ្នែកតេត្រាស៊ីគ្លីន១% ទៅក្នុងភ្នែកសងខាងរបស់ទារក ក្នុងអំឡុង២ម៉ោងដំបូងបន្ទាប់ពីសម្រាល។ ***ឬ***
- បន្តក់មួយដំណក់នៃថ្នាំប្រូវីដុនអ៊ីយ៉ូឌីន(povidone-iodine) ២,៥% ទៅក្នុងភ្នែកទាំងសងខាងរបស់ទារក ក្នុងអំឡុងពេល២ម៉ោងដំបូងបន្ទាប់ពីសម្រាល។

នៅកន្លែងខ្លះ គេប្រើថ្នាំបាក្រ់នីត្រាត១% (ឬថ្នាំភ្នែកផ្សេងទៀត)ដាក់ភ្នែករបស់ទារក។ ថ្នាំទាំងនេះប្រឆាំងនឹងការខ្វាក់ភ្នែកដោយជំងឺប្រមេះទឹកបាយ តែវាមិនអាចបញ្ឈប់ការខ្វាក់ដោយសារជំងឺក្លាមីដ្យាទេ។ ម៉្យាងទៀត ថ្នាំបាក្រ់នីត្រាត ក៏ធ្វើឲ្យក្រហាយភ្នែកទារករយៈពេលជាច្រើនថ្ងៃ។ ប្រសិនបើអ្នកអាចរកថ្នាំអេរីត្រូមីស៊ីន ឬតេត្រាស៊ីគ្លីនបាន ប្រើថ្នាំណាមួយក្នុងចំណោមទាំងពីរនេះ។ ប៉ុន្តែប្រើថ្នាំបាក្រ់នីត្រាត បើអ្នកមានតែថ្នាំនេះ។

បើទារកកើតជំងឺប្រមេះទឹកបាយ ឬក្លាមីដ្យានៅភ្នែក ឪពុកម្ដាយក៏ត្រូវទទួលការព្យាបាលជំងឺទាំងនេះផងដែរ (ទំ.២៣៧ និង៣៦០)។

# ជំងឺរលាកប្រស្រីភ្នែក

ភ្នែកធម្មតា



ភ្នែកមានជំងឺរលាកប្រស្រីភ្នែក



*រោគសញ្ញា ៖*

*កូនក្រមុំភ្នែកតូច ហើយមានគែមមិនស្មើ មានក្រហមជុំវិញប្រស្រីភ្នែក មានការឈឺចាប់ខ្លាំង។*

តាមធម្មតា ជំងឺរលាកប្រស្រីភ្នែកកើតលើភ្នែកតែម្ខាងប៉ុណ្ណោះ។ ការឈឺចាប់អាចចាប់ផ្ដើមឡើងភ្លាមៗ ឬបន្តិចម្ដងៗ។ ភ្នែកមានចេញទឹកភ្នែកយ៉ាងច្រើន ហើយមានការឈឺចាប់កាន់តែខ្លាំងពេលត្រូវពន្លឺថ្ងៃ។ គ្រាប់ភ្នែកមានការឈឺចាប់នៅពេលដែលអ្នកប៉ះវា។ គ្មានខ្ទុះ ដូចជាជំងឺរលាកផ្ទៃកសនៃភ្នែកទេ។ ជាធម្មតាវាមានការព្រិលភ្នែក។ **នេះគឺជាករណីបន្ទាន់។** ថ្នាំក្រមួនអង់ទីប៊ីយ៉ូទិកមិនអាចជួយបានទេ។ **ត្រូវរកជំនួយពីគ្រូពេទ្យ។**

# ជំងឺភ្លូកូម

ជំងឺដ៏គ្រោះថ្នាក់នេះបណ្ដាលមកពីការមានសម្ពាធយ៉ាងខ្លាំងនៅក្នុងភ្នែក។ វាច្រើនតែកើតឡើងនៅបន្ទាប់ពីមានអាយុ ៤០ឆ្នាំឡើងទៅ ហើយវាជាមូលហេតុយ៉ាងញឹកញាប់នៃការខ្វាក់ភ្នែក។ **ដើម្បីបង្ការការខ្វាក់ភ្នែក ជាការសំខាន់គឺត្រូវស្គាល់រោគសញ្ញានៃជំងឺភ្លូកូមនេះ និងត្រូវរកជំនួយពីគ្រូពេទ្យឲ្យបានឆាប់។**

ជំងឺភ្លូកូមមានពីរយ៉ាង ៖

## ជំងឺភ្លូកូមធ្ងន់ធ្ងរ

វាចាប់ផ្ដើមភ្លាមៗដោយមានការឈឺក្បាល ឬមានការឈឺចាប់យ៉ាងខ្លាំងនៅក្នុងភ្នែក។ ភ្នែកចាប់ផ្ដើមឡើងក្រហម និងមើលមិនច្បាស់។ បើយើងស្ទាប គ្រាប់ភ្នែកមានសភាពរឹង ដូចជាថ្ម។ អាចមានការក្អួតចង្អោរ។ នៅភ្នែកដែលមានបញ្ហាកូនក្រមុំភ្នែករីកធំ ជាងកូនក្រមុំភ្នែកធម្មតា។




បើគ្មានការព្យាបាលជាបន្ទាន់ទេ ជំងឺភ្លូកូមធ្ងន់ធ្ងរនឹងបណ្ដាលឲ្យខ្វាក់ក្នុងអំឡុងពេលពីរឬបីថ្ងៃ។ ជាញឹកញាប់ គេត្រូវការការវះកាត់។ **ត្រូវរកជំនួយពីគ្រូពេទ្យជាបន្ទាន់។**

## ជំងឺភ្លូកូមរ៉ាំរ៉ៃ

សម្ពាធនៅក្នុងភ្នែកកើនឡើងយឺតៗ។ ជាញឹកញាប់ គ្មានការឈឺចាប់ទេ។ មានការបាត់បង់គំហើញយឺតៗ ដោយចាប់ផ្ដើមពីចំហៀងមក ហើយភាគច្រើនអ្នកជំងឺមិនបានចាប់អារម្មណ៍អំពីការបាត់បង់នេះទេ។ ការធ្វើតេស្ដ៍មើលគំហើញចំហៀង អាចជួយឲ្យរកឃើញជំងឺនេះបាន។

**ការធ្វើតេស្ដ៍រកជំងឺភ្លូកូម**




បើជំងឺត្រូវបានឆាប់រកឃើញ នោះការព្យាបាលដោយថ្នាំដាក់ភ្នែកពិសេស ( ពីឡូកាពីន pilocarpine ) អាចបង្ការការខ្វាក់បាន។ កម្រិតប្រើថ្នាំគួរបានកំណត់ដោយគ្រូពេទ្យ ឬបុគ្គលិកសុខាភិបាលដែលអាចវាស់សម្ពាធភ្នែក ដោយទៀងទាត់បាន។ ថ្នាំដាក់ភ្នែកត្រូវប្រើអស់មួយជីវិត។ បើអាច ការវះកាត់ភ្នែកជាការព្យាបាលដែលប្រាកដបំផុត។

### *វិធីការពារ*

មនុស្សដែលមានអាយុលើសពី៤០ឆ្នាំ ឬមានសាច់ញាតិកើតជំងឺភ្លូកូម គួរព្យាយាមធ្វើការពិនិត្យសម្ពាធភ្នែកឲ្យបានម្ដងក្នុង១ឆ្នាំ។

## ការបង្ករោគនៅក្រពេញទឹកភ្នែក

*រោគសញ្ញា*

ការឡើងក្រហម មានការឈឺចាប់ និងមានការហើម នៅខាងក្រោមភ្នែក ក្បែរច្រមុះ។ ភ្នែកមានចេញទឹកភ្នែកយ៉ាងច្រើន។ អាចមានការចេញខ្ទុះតាមគែមភ្នែក នៅពេលគេសង្កត់ថ្នមៗត្រង់កន្លែងហើម។



*វិធីព្យាបាល*

- ស្អំដោយក្រណាត់ក្តៅ
- ដាក់ទឹកថ្នាំភ្នែកអង់ទីប៊ីយ៉ូទិក ឬថ្នាំក្រមួនដាក់ភ្នែក
- លេបថ្នាំប៉េនីស៊ីលីន ( Penicillin ) ( ទំ.៣៥១ )

## ភ្នែកមើលមិនច្បាស់

**ចំពោះកុមារ**ដែលមានភ្នែកមើលមិនច្បាស់ ឬមានការឈឺក្បាល ឬឈឺភ្នែកពេលដែលពួកគេអានអក្សរ គេអាចត្រូវការប្រើវ៉ែនតា។ ពិនិត្យមើលភ្នែករបស់ពួកគេ។

**ចំពោះមនុស្សចាស់** វាជាការធម្មតាទេ កាលណាមានអាយុច្រើន តែងតែមានការពិបាកក្នុងការមើលវត្ថុជិតៗឲ្យបានច្បាស់។ ការប្រើវ៉ែនតាអានអក្សរ អាចជួយបាន។ ជ្រើសរើសយកវ៉ែនតាដែលអាច ឲ្យអ្នកមើលឃើញច្បាស់ក្នុងចំងាយប្រហែល៤០សង្ទីម៉ែត្រពីភ្នែករបស់អ្នក។ បើវ៉ែនតាមិនអាចជួយបានទៀត ត្រូវទៅជួបគ្រូពេទ្យភ្នែក។



## ភ្នែកគេក ឬភ្នែកស្រលៀង

ប្រសិនបើជួនកាលភ្នែកស្រលៀងដូចនេះ ប៉ុន្តែពេលខ្លះទៀតអាចសំឡឹងមើលទៅមុខដោយធម្មតាវិញ នោះអ្នកមិនចាំបាច់ព្រួយបារម្ភទេ។ ភ្នែកនេះនឹងវិវឌ្ឍន៍ទៅជាត្រង់វិញបាននៅពេលណាមួយ។ ប៉ុន្តែបើភ្នែកតែងតែបែរទៅតែម្ខាងជានិច្ច ហើយប្រសិនបើកុមារនោះមិនបានទទួលការព្យាបាលនៅពេលមានអាយុតិចទេ ភ្នែកនោះប្រហែលជានឹងមិនអាចមើលឃើញបានល្អទេ។ ទៅជួបគ្រូពេទ្យភ្នែកឲ្យបានលឿនតាមដែលអាចធ្វើបាន ដើម្បីពិនិត្យមើលថាតើការគ្របភ្នែកម្ខាងដែលល្អ ការវះកាត់ ឬការប្រើវ៉ែនតាពិសេស អាចជួយបានឬទេ។



ការវះកាត់នៅអាយុច្រើនបន្តិច អាចតម្រង់ភ្នែកឲ្យត្រង់ និងធ្វើឲ្យកុមារលូតលាស់ពេញលក្ខណៈ ប៉ុន្តែនឹងមិនអាចជួយភ្នែកដែលខ្សោយឲ្យមើលឃើញច្បាស់បានទេ។

*សំខាន់ ៖* គំហើញរបស់កុមារគ្រប់រូប គប្បីត្រូវបានពិនិត្យឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ( ល្អបំផុតគឺនៅអាយុប្រហែល៤ឆ្នាំ )។ អ្នកអាចប្រើតារាងអក្សរ "អ៊ី" សម្រាប់ពិនិត្យភ្នែកបាន។ ធ្វើតេស្តភ្នែកនីមួយៗដោយឡែកពីគ្នា ដើម្បីស្វែងរកបញ្ហាដែលប៉ះពាល់ដល់ភ្នែកតែម្ខាង។ បើភ្នែកតែម្ខាងឬទាំងសងខាង មើលមិនច្បាស់ ទៅជួបគ្រូពេទ្យភ្នែក។



## ពពំភ្នែក

ដុំពកក្រហម ហើម នៅត្របកភ្នែក ច្រើនតែនៅជិតគែមត្របកភ្នែក។ ដើម្បីព្យាបាល ស្អំដោយកុំប្រេសក្តៅឧណ្ហៗជ្រើមដោយទឹកដែលមានដាក់អំបិលបន្តិច។ ការប្រើក្រមួនដាក់ភ្នែកអង់ទីប៊ីយ៉ូទិក៣ដងក្នុង១ថ្ងៃនឹងជួយបង្ការការកើតពពំភ្នែកនេះទៀត។



## កន្ទុយថ្លែន

សាច់ក្រាស់នៅលើផ្ទៃភ្នែកដែលរីកធំឡើងបន្តិចម្តងៗពីផ្នែកសនៃភ្នែកដែលនៅខាងច្រមុះ ទៅគ័រនេ។ ផ្នែកមួយនៃមូលហេតុរបស់បញ្ហានេះគឺបណ្តាលមកពីពន្លឺថ្ងៃ ខ្យល់ និងធូលី។ វ៉ែនតាខ្មៅអាចជួយបន្ថយការក្រហាយ និងបន្ថយល្បឿននៃការលូតលាស់របស់កន្ទុយថ្លែននេះ។ កន្ទុយថ្លែនគួរត្រូវបានវះកាត់ចេញមុនពេលវារីកដល់កូនក្រមុំភ្នែក។ ជាអកុសល ក្រោយពេលវះកាត់ហើយ កន្ទុយថ្លែនច្រើនតែកើតឡើងវិញ។



ការព្យាបាលតាមវិធីបុរាណដោយប្រើម្សៅសំបកខ្យងធ្វើឲ្យមានផលអាក្រក់ច្រើនជាងផលល្អ។ ដើម្បីជួយសម្រាលការរមាស់និងការក្រហាយ អ្នកអាចសាកល្បងស្អំដោយក្រណាត់ត្រជាក់។ ឬប្រើថ្នាំដំណក់ភ្នែកដែលមានជាតិកាម៉ូមីល (ស្ងោរឲ្យពុះល្អ រួចត្រង ទុកឲ្យត្រជាក់ កុំដាក់ស្ករ)។

## ការរលាត់ ដំបៅ ឬសម្លាកនៅលើគ័រនេ

នៅពេលដែលផ្ទៃដ៏ស្តើងនៃគ័រនេមានការរលាត់ ឬត្រូវបានបំផ្លាញដោយសារការបង្ករោគ អាចបណ្តាលឲ្យមាន**ដំបៅនៅគ័រនេ**ដែលមានការឈឺចាប់យ៉ាងខ្លាំង។ បើអ្នកពិនិត្យឲ្យបានហ្មត់ចត់ ក្រោមពន្លឺដ៏ល្អ អ្នកអាចឃើញស្នាមពណ៌ប្រផេះ ឬស្រអាប់ស្ថិតនៅលើគ័រនេ។



បើគ្មានការថែរក្សាជិតដល់ទេ ដំបៅលើគ័រនេនេះ អាចបណ្តាលឲ្យខ្វាក់ភ្នែក។ ដាក់ក្រមួនដាក់ភ្នែកអង់ទីប៊ីយ៉ូទិក៤ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ និងឲ្យថ្នាំប៉េនីស៊ីលីន(ទំ.៣៥១) ហើយគ្របភ្នែកដែលមានដំបៅនោះ។ បើគ្មានការធូរស្រាលក្នុងរយៈពេលពីរថ្ងៃទេ ត្រូវរកជំនួយពីគ្រូពេទ្យ។

សម្លាកលើគ័រនេ គឺជាស្នាមពណ៌សដែលគ្មានការឈឺចាប់។ វាអាចបណ្តាលមកពីការជាសះស្បើយនៃដំបៅលើគ័រនេ ការរលាក ឬការមានរបួសផ្សេងៗទៅលើភ្នែក។ ប្រសិនបើភ្នែកទាំងពីរខ្វាក់ ប៉ុន្តែមនុស្សនោះនៅមើលឃើញពន្លឺ នោះការវះកាត់ប្តូរគ័រនេរបស់ភ្នែកម្ខាង អាចធ្វើឲ្យមើលឃើញវិញ។ ប៉ុន្តែការព្យាបាលរបៀបនេះមានតម្លៃថ្លៃណាស់។ ប្រសិនបើភ្នែកម្ខាងមានសម្លាក ប៉ុន្តែម្ខាងទៀតមើលឃើញល្អ កុំវះកាត់។ ថែរក្សាភ្នែកដែលនៅល្អ កុំឲ្យមានរបួស។



## ការហូរឈាមក្នុងផ្នែកសនៃភ្នែក



ស្នាមក្រហមដូចឈាមហើយមិនឈឺ ដែលនៅក្នុងផ្នែកសនៃភ្នែក អាចកើតមានយូរៗម្តងបន្ទាប់ពីមានការលើកវត្ថុធ្ងន់ ការក្អកខ្លាំង( ដូចជាក្អកមាន់ ) ឬត្រូវគេដាល់ត្រូវភ្នែក។ ស្ថានភាពនេះជាលទ្ធផលនៃការបែកធ្លាយសរសៃឈាមតូចៗ។ វាគ្មានគ្រោះថ្នាក់អ្វីទេ ដូចជាស្នាមជាំមួយដែរ ហើយនឹងបាត់ទៅវិញបន្តិចម្តងៗដោយមិនបាច់ព្យាបាលក្នុងអំឡុងពេលប្រហែល២សប្តាហ៍។

ស្នាមក្រហមតូចៗទាំងនេះច្រើនកើតនៅលើភ្នែកទារកដែលទើបសម្រាល។ គេមិនត្រូវការការព្យាបាលទេ។

## ការហូរឈាមនៅខាងក្រោយគ័រនេ



ការហូរឈាមនៅខាងក្រោយគ័រនេ គឺជារោគសញ្ញាដ៏គ្រោះថ្នាក់មួយ។ វាតែងតែបណ្តាលមកពីមានការប៉ះទង្គិចទៅលើភ្នែកដោយវត្ថុទាល ដូចជាកណ្តាប់ដៃ។ បើមានការឈឺចាប់ និងបាត់បង់គំហើញ បញ្ជូនអ្នករងគ្រោះទៅអ្នកជួបគ្រូពេទ្យភ្នែកជាបន្ទាន់។ បើមានការឈឺចាប់បន្តិចបន្តួច និងគ្មានការបាត់បង់គំហើញទេ គ្របភ្នែកទាំងពីរ និងឲ្យសម្រាកលើគ្រែជាច្រើនថ្ងៃ។ បើ២ឬ៣ថ្ងៃក្រោយមក ការឈឺចាប់ក្លាយជាកាន់តែធ្ងន់ធ្ងរ ប្រហែលជាមានបញ្ហាតឹងក្នុងភ្នែក( ជំងឺគ្លូកូម ទំ.២២២ )។ ជូនអ្នកជំងឺទៅជួបគ្រូពេទ្យភ្នែក**ជាបន្ទាន់**។

## ការមានខ្ទុះនៅខាងក្រោយគ័រនេ



ការមានខ្ទុះនៅខាងក្រោយគ័រនេ គឺជារោគសញ្ញានៃ*ការរលាក* ធ្ងន់ធ្ងរ។ ជួនកាលគេឃើញមានដំបៅគ័រនេ និងជាសញ្ញាបង្ហាញថាភ្នែកកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់។ ឲ្យថ្នាំប៉េនីស៊ីលីន( ទំ.៣៥១ ) រួចរកជំនួយ ពីគ្រូពេទ្យជាបន្ទាន់។ បើដំបៅត្រូវបានព្យាបាលដោយត្រឹមត្រូវ ខ្ទុះនោះនឹងបានជាសះស្បើយទៅវិញ។

## ភ្នែកឡើងបាយ



កញ្ចក់ភ្នែកដែលនៅពីក្រោយកូនក្រមុំភ្នែក ក្លាយជាមានពណ៌សស្រអាប់ ធ្វើឲ្យកូនក្រមុំភ្នែកហាក់ដូចជាមានពណ៌ប្រផេះឬពណ៌ស នៅពេលដែលអ្នកបញ្ចាំងពន្លឺទៅក្នុងភ្នែកនោះ។ ភ្នែកឡើងបាយច្រើនកើតលើមនុស្សចាស់ ប៉ុន្តែក៏អាចកើតឡើងដោយកម្រ លើទារកដែរ។ បើមនុស្សងងឹតភ្នែកដោយសារភ្នែកឡើងបាយ អាចមើលឃើញពន្លឺនៅកន្លែងងងឹត ហើយអាចកត់សំគាល់ចលនាអ្វីមួយ នោះការវះកាត់អាចធ្វើឲ្យគាត់មើលឃើញវិញបាន។ ទោះបីជាយ៉ាងនេះក៏ដោយ គាត់នឹងត្រូវប្រើវ៉ែនតាក្រាស់ៗ បន្ទាប់ពីការវះកាត់រួច ដែលនឹងត្រូវប្រើពេលមួយរយៈដើម្បីមានទម្លាប់ជាមួយវ៉ែនតានោះ។ ថ្នាំពេទ្យមិនអាចជួយព្យាបាលការភ្នែកឡើងបាយបានទេ។ ( សព្វថ្ងៃនេះ ជួនកាលក្នុងពេលវះកាត់ គេអាចដាក់កញ្ចក់ភ្នែកសិប្បនិម្មិត ដូច្នេះគេមិនចាំបាច់ប្រើវ៉ែនតាក្រាស់ៗទេ )។

# ខ្វាក់មាន់ និងជំងឺភ្នែកស្ងួត (ការខ្វះវីតាមីនអា)



ជំងឺភ្នែកនេះច្រើនកើតចំពោះកុមារដែលមានអាយុពី១ឆ្នាំទៅ៥ឆ្នាំ។ វាកើតដោយសារមិនបានបរិភោគចំណីអាហារដែលមានវីតាមីនអាគ្រប់គ្រាន់។ បើយើងមិនស្គាល់ និងមិនបានព្យាបាលឲ្យទាន់ពេលទេ វាអាចធ្វើឲ្យកុមារខ្វាក់បាន។

*រោគសញ្ញា ៖*

- ដំបូងកុមារអាចកើត**ជំងឺខ្វាក់មាន់**។ គាត់ក៏មិនអាចមើលឃើញនៅកន្លែងងងឹត ដែលមនុស្សឯទៀតអាចមើលឃើញ។
- បន្ទាប់មកគាត់កើតមានជំងឺ**ភ្នែកស្ងួត**។ ផ្នែកសនៃភ្នែកបានបាត់បង់ភាពរលោង ហើយចាប់ផ្ដើមជ្រួញ។



- មានស្នាមពពុះតូចៗពណ៌ប្រផេះអាចកើតឡើងក្នុងភ្នែក។
- នៅពេលជំងឺនេះមានសភាពកាន់តែធ្ងន់ធ្ងរ គ័រនេក៏ប្រែក្លាយទៅជាស្ងួតនិងស្រអាប់ ហើយអាចមានប្រហោងតូចៗ។



- បន្ទាប់មកគ័រនេអាចប្រែជាទន់យ៉ាងឆាប់រហ័ស ប៉ោងលៀន ឬអាចបែកធ្លាយផងក៏មាន។ តាមធម្មតា គ្មានការឈឺចាប់ទេ។ ការមើលមិនឃើញអាចបណ្ដាលមកពីការបង្ករោគ សម្លាក ឬដោយការខូចខាតផ្សេងទៀត។
- ជំងឺភ្នែកស្ងួតភាគច្រើនចាប់ផ្ដើមឡើង ឬកាន់តែខ្លាំងឡើង នៅពេលកុមារមានជំងឺផ្សេងទៀតដូចជា រាក ក្អកមាន់ របេង ឬកញ្ជ្រឹល។ **ត្រូវពិនិត្យភ្នែករបស់កុមារទាំងអស់ដែលមានជំងឺ និងកុមារដែលស្គមៗ** បើកភ្នែករបស់កុមារ ហើយរកមើលរោគសញ្ញានៃការខ្វះវីតាមីនអា។



*ការការពារ និងការព្យាបាល ៖*

ជំងឺភ្នែកស្ងួតអាចការពារបានយ៉ាងងាយ ដោយការបរិភោគអាហារដែលមានវីតាមីនអា។ ធ្វើដូចការរៀបរាប់ខាងក្រោមនេះ ៖

- បំបៅកូនដោយទឹកដោះម្ដាយរហូតអាយុបាន២ឆ្នាំ បើអាចធ្វើបាន។
- បន្ទាប់ពី៦ខែដំបូង ត្រូវចាប់ផ្ដើមឲ្យកុមារបរិភោគអាហារសំបូរវីតាមីនអា ដូចជាបន្លែដែលមានស្លឹកពណ៌បៃតងចាស់ និងផ្លែឈើពណ៌លឿងឬក្រហម ដូចជាផ្លែល្ហុង ស្វាយ និងផ្លែល្ពៅ។ ទឹកដោះគោ ស៊ុត និងថ្លើម ក៏សំបូរវីតាមីនអាដែរ។
- បើកុមារហាក់ដូចជាមិនបានទទួលអាហារទាំងនេះទេ ឬ បើកុមារមានរោគសញ្ញាខ្វាក់មាន់ ឬភ្នែកស្ងួត ឲ្យគាត់លេបថ្នាំគ្រាប់ជីវជាតិអា ២០០.០០០អ៊ុយនីតេ (៦០មីលីក្រាម រ៉េទីណុល retinol ជាថ្នាំគ្រាប់ ឬជាទឹកស៊ីរ៉ូ)រៀងរាល់៦ខែម្ដង (ទំ.៣៩២)។ ទារកដែលមានអាយុក្រោម១ឆ្នាំ គួរទទួល ១០០.០០០អ៊ុយនីតេ។



- បើជំងឺមានស្ថានភាពធ្ងន់ធ្ងររួចទៅហើយ ត្រូវឲ្យកុមារនោះលេបវីតាមីនអា ២០០.០០០អ៊ុយនីតេនៅថ្ងៃទី១។ ២០០.០០០អ៊ុយនីតេទៀតនៅថ្ងៃទី២ និង ២០០.០០០អ៊ុយនីតេទៀតនៅ១៤ថ្ងៃក្រោយមក។ ទារកដែលមានអាយុក្រោម១ឆ្នាំ គប្បីលេបពាក់កណ្តាលនៃកម្រិតថ្នាំនេះ(១០០,០០០អ៊ុយនីតេ)។
- នៅក្នុងសហគមន៍ដែលសំបូរជំងឺភ្នែកស្ងួត ឲ្យថ្នាំជីវជាតិអា ២០០.០០០អ៊ុយនីតេ ទៅស្ត្រីដែលកំពុងបំបៅដោះកូន រៀងរាល់៦ខែម្តង និងឲ្យទៅស្ត្រីមានផ្ទៃពោះចាប់ពីបួនខែកន្លះ។

*បំរាម ៖* ការឲ្យថ្នាំជីវជាតិអាច្រើនពេក បណ្តាលឲ្យពុល។ មិនត្រូវឲ្យថ្នាំលើសពីការណែនាំទេ។

បើភ្នែករបស់កុមារមានសភាពធ្ងន់ធ្ងរ ដោយមានគំរនេឡើងល្អក់ មានប្រហោង ឬប៉ោង ត្រូវរកជំនួយពីគ្រូពេទ្យជាបន្ទាន់។ ភ្នែករបស់កុមារគួរត្រូវរុំបិទ ហើយកុមារគួរលេបថ្នាំជីវជាតិអាភ្លាមៗ យកល្អគួរចាក់ថ្នាំជីវជាតិអា១០០.០០០អ៊ុយនីតេ។

**បន្លែដែលមានស្លឹកពណ៌បៃតងចាស់ និងផ្លែឈើពណ៌លឿងឬផ្លែក្រូច និងបន្លែផ្សេងៗ ជួយបង្ការការខ្វាក់ភ្នែកលើកុមារ។**

## ចំណុចតូចៗនៅខាងមុខភ្នែក ឬមើលឃើញបែកផ្សែង

ជួនកាលមនុស្សចាស់ត្អូញត្អែរថាមានចំណុចតូចៗមានចលនានៅពីមុខគាត់ ពេលគាត់សំឡឹងមើលផ្ទៃភ្លឺមួយ(ជញ្ជាំង ឬផ្ទៃមេឃ)។ ចំណុចទាំងនោះមានចលនានៅពេលដែលភ្នែកមានចលនា ហើយមើលទៅដូចសត្វរុយតូចៗ។ ធម្មតាចំណុចទាំងនេះមិនមានគ្រោះថ្នាក់អ្វីទេ ហើយក៏មិនចាំបាច់ព្យាបាលដែរ។ ប៉ុន្តែបើចំណុចទាំងនោះមានកាន់តែច្រើនឡើងៗក្នុងពេលដ៏ខ្លី ហើយគំហើញចាប់ផ្តើមធ្លាក់ចុះពីចំហៀងណាមួយ នេះអាចជាបញ្ហាដែលត្រូវការការសង្គ្រោះបន្ទាន់ (ការដាច់ចេញនៃរ៉េទីនរបស់ភ្នែក)។ **ត្រូវរកជំនួយពីគ្រូពេទ្យជាបន្ទាន់។**

## ព្រិលភ្នែក មើលបែករូបជាពីរ



ការមើលឃើញបែករូបជាពីរ អាចបណ្តាលមកពីមូលហេតុច្រើនយ៉ាង។

ប្រសិនបើការមើលឃើញបែករូបជាពីរកើតឡើងភ្លាមៗ ឬកើតឡើងរ៉ាំរ៉ៃ ឬកាន់តែធ្ងន់ធ្ងរបន្តិចម្តងៗ នេះប្រហែលជារោគសញ្ញានៃបញ្ហាធ្ងន់ធ្ងរមួយ។ ត្រូវរកជំនួយពីគ្រូពេទ្យ។

ប្រសិនបើការមើលឃើញបែករូបជាពីរនេះកើតឡើងម្តងម្កាលទេ វាអាចជារោគសញ្ញានៃភាពខ្សោយ ឬអស់កម្លាំង ដែលប្រហែលជាមកពីការខ្វះអាហារូបត្ថម្ភ។ មើលជំពូក១១ អំពីអាហារូបត្ថម្ភត្រឹមត្រូវ ហើយត្រូវខំប្រឹងបរិភោគឲ្យបានត្រឹមត្រូវ បើអាចធ្វើបាន។ បើគំហើញគ្មានការប្រសើរទេ ត្រូវរកជំនួយពីគ្រូពេទ្យ។

អត្ថបទក្នុងទំព័រ ២២៨
មិនត្រូវបានបញ្ចូលក្នុងការបោះពុម្ពជាភាសាខ្មែរនេះទេ

